ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ០៩

ចុះថ្ងៃទី២៥ខែមករាឆ្នាំ១៩៩៩

សាលដីកា

លេខ : ៣៨

ចុះថ្ងៃទី០៣ខែធ្នូឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២ - លោក ប៉ែន ស៊ិន ជាចៅក្រម

៣ - លោក ប្រាក់ គឹមសាន ជាចៅក្រម

៤ - លោក សោម សិរីវុឌ្ឍ ជាចៅក្រម

៥ - លោក ឃស់ សុខឿន ជាចៅក្រម **របាយការណ៍**

លោក ខាន់ បូរ៉ាត ជាក្រឡាបញ្ជី

តំណាងមហាអយ្យការលោក ជួន ស៊ុនលៀង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ០៩ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ-១៩៩៩ របស់តុលាការកំពូល ។

ពីបទ : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តកាលពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ នៅភូមិ ២០ឧសភា ឃុំ-ស្រុក ឯករាជ ខេត្តបាត់ដំបង បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៤១.៦៣និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១ - ជនជាប់ចោទឈ្មោះ ជា លីអៀង " ម្ចាស់បណ្តឹងសាទុក្ខ " ភេទស្រី អាយុ ៣៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ តាមរនាទី ឃុំតាមរនាទីស្រុកកញ្ឈាម ខេត្តព្រៃវែង មុខរបរ លក់ដូរ ទីលំនៅបច្ចុប្បន្ន ភូមិ២០ឧសភា ឃុំ-ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ម៉ៅ លី "ស្លាប់" ម្តាយឈ្មោះ ជា មួយ " រស់ " ប្តីឈ្មោះ សេក សំបូរ មានកូន ០៣នាក់ នៅក្រៅឃុំ ។

- មេធាវីលោក គង់ ពិសី

២ - ជនជាប់ចោទឈ្មោះ សេក សំបូរ " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរកើតនៅភូមិ គងទុំ ឃុំ តាម៉ឯក ស្រុក - ខេត្តបាត់ដំបង ។ មុខរបរ នគរបាលព្រហ្មទណ្ឌខេត្ត មានទីលំនៅបច្ចុប្បន្ន ភូមិ២០ឧសភា ឃុំ-ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ពិន ឡុង "ស" ម្តាយឈ្មោះ គឹម ធួន "ស" ប្រពន្ធឈ្មោះ ជា លីអៀង មានកូន០៣នាក់ នៅក្រៅឃុំ ។

- មេធាវីលោក គង់ ពិសី

៣ - ជនជាប់ចោទឈ្មោះ ពេង គឹមហួយ ភេទស្រី អាយុ ២៣ ឆ្នាំជាតិខ្មែរ កើតនៅភូមិ ឃុំ ចំការសំរោង ស្រុក- ខេត្តបាត់ដំបង មុខរបរលក់ដូរ ឪពុកឈ្មោះ ពេង ពេង "រស់" ម្ដាយឈ្មោះ ឃីម ក៏កង "ស្លាប់" នៅលីវ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

៤ - ជនរងគ្រោះឈ្មោះ ឃីម នី "ជាចុងបណ្ដឹងសាទុក្ខ" ភេទស្រី អាយុ ៣៨ ឆ្នាំជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅភូមិ២០ឧសភា ឃុំ - ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង ។

- មេធាវី គ្មាន

៥ - ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ លោក សំបូរ "ជាម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុសអាយុ-៣៩ ឆ្នាំជាតិ ខ្មែរ មុខរបរ នគរបាលខេត្តបាត់ដំបង ទីលំនៅ ភូមិ ២០ឧសភា ឃុំ-ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

- តាមបណ្ដឹងសាទុក្ខលេខ ៤២ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះលោក សំបូរ និងឈ្មោះ ជា ស៊ីអៀង ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ស្នើសេចក្ដីសំរេចទាំងមូល ។

- តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៣ - ៩ - ៩៤ របស់ឈ្មោះ ឃីម នី ប្ដឹងពីឈ្មោះ លោក សំបូរ និងប្រពន្ធឈ្មោះ ជា ស៊ីអៀង ដែលបាននាំយកខ្លួននិងប្អូនស្រីខ្លួនឈ្មោះ ពេង គឹមហួយ កាលពីថ្ងៃទី ០២-៩ - ៩៤ ដោយពេលនោះខ្លួនមានផ្ទៃពោះ៦ខែ ។ ខ្លួនប្ដឹងសុំអោយឈ្មោះ លោក សំបូរ សងថ្លៃថ្នាំពេទ្យព្យាបាលនិងកំរៃប្រចាំថ្ងៃ ដែលអាក់ខាតក្នុងការព្យាបាល និងបញ្ឈប់ផ្ទៃពោះជាបន្ទ ។

- តាមពាក្យបណ្ដឹងចុះថ្ងៃទី ២១ - ១១ - ៩៤ របស់ឈ្មោះ លោក សំបូរ ប្ដឹងពីឈ្មោះឃីម នី និងឈ្មោះពេង គឹមហួយ ពីបទបង្ករបួសស្នាមដោយចេតនា រំលោភសិទ្ធិបុគ្គល និងការបរិហារកេរ្តិ៍ ។ ខ្លួនប្ដឹងសុំអោយឈ្មោះ ឃីម នី . ឃីម ណារិទ្ធិ និងពេង គឹមហួយ ជួសជុលសំណងអន្តរាយ ដែលបានប្រព្រឹត្តអំពើ ព្យសនកម្ម មកលើក្រុមគ្រួសាររបស់ខ្លួន ជាទឹកប្រាក់ ៥ លានរៀល និងសុំអោយជនទាំងបីទទួលខុសត្រូវក្នុងការបាត់ខ្សែករធ្លាក់ទីនទំងន់១ជី២ហ៊ុន និងបន្ដោងត្បូងបរទេសប៉ៃលិន គិតជាប្រាក់ស្មើ-០១លានរៀល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តបាត់ដំបង បានសំរេចៈ

មានភស្តុតាង និងមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ជា ស៊ីអៀង និងឈ្មោះ លោក-សំបូរ ពីបទបង្ករបួសស្នាមដោយចេតនា និងជេរប្រមាថ ប្រព្រឹត្តនៅភូមិ២០ឧសភា ឃុំ- ស្រុកស្វាយ-ប៉ោ ខេត្តបាត់ដំបងកាលពីថ្ងៃទី ២២ - ៩ - ៩៤ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្ដន្ទាទោសតាមមាត្រា៤១និងមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

តម្កល់បទចោទទុកជាបានការ និងស្នើសុំអោយតុលាការផ្ដន្ទាទោសលើឈ្មោះជា ស៊ីអៀង ដាក់ពន្ធនាគារកំណត់២ខែសល់៦ខែ និងសុំអោយផ្ដន្ទាទោសលើឈ្មោះ លោក សំបូរ ដាក់ពន្ធនាគារ. កំណត់ ៤ខែសល់២ខែ ។

សំរេចដកបណ្ដឹងអាជ្ញាលើឈ្មោះ ពេង គឹមហួយ តាមដីកាសន្និដ្ឋានស្ថាពរលេខ ១២៥ដែលបាន ចុះថ្ងៃទី ៣១ - ០១ - ៩៥ ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ២០ឧសភា ឃុំ- ស្រុក-

ស្វាយចេក ខេត្តបាត់ដំបង កាលពីថ្ងៃទី ២២-៤-៩៥ ។

- ដីកាលើកលែងចោទប្រកាន់លេខ ២៧១ ពណ.ព្រព ចុះថ្ងៃទី ០៦-០២-៩៥ លើឈ្មោះ ឃឹម ស៊ាវរី ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ២០ឧសភា ឃុំឯកភាព ទីរួម ខេត្តបាត់ដំបង កាលពីថ្ងៃទី ២២-៤-៩៥ ។

- ដីកាលើកលែងចោទប្រកាន់លេខ ២៧២ពណ.ព្រព ចុះថ្ងៃទី ០៦-០២-៩៥ លើឈ្មោះ ឃឹម នី ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ២០ឧសភា ឃុំឯកភាព ទីរួមខេត្តបាត់ដំបង កាលពីថ្ងៃទី ២២-៤-៩៥ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦០ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់តុលាការខេត្តបាត់ដំបង ដែលបានសំរេច :

១ - ក - ផ្ដន្ទាទោសលើឈ្មោះ សេក សំបូរ ដាក់ពន្ធនាគារកំណត់ ៦ ខែតែទោសនេះត្រូវព្យួររយៈពេលសាកល្បង ៥ ឆ្នាំ ពីបទ បង្ករបួសស្នាមដោយចេតនានិងជេរប្រមាថ ។

ខ - ផ្ដន្ទាទោសលើឈ្មោះ ជា ស៊ីអៀង ដាក់ពន្ធនាគារកំណត់ ៣ ខែតែទោសនេះត្រូវព្យួរ រយៈពេលសាកល្បង ៥ ឆ្នាំ ពីបទ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបាត់ដំបង កាលពីថ្ងៃទី ២២-៤-៩៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៥១-៦៣-៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-៩២ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ។

២ - អោយឈ្មោះ សេក សំបូរ និងឈ្មោះ ជា ស៊ីអៀង រួមគ្នាសងទៅឈ្មោះ ឃឹម នី ជាដើមបណ្ដឹងនូវសំណងពព្យាបាល គិតជាប្រាក់រៀលស្មើនឹងតំម្លៃមាសទឹកដប់ចំនួន ០១ ជីនិងសំណងជំងឺចិត្តគិតជាប្រាក់រៀលស្មើនឹងតំម្លៃ ៥ ជីមាសទឹកដប់ ។ ដើមបណ្ដឹងទាមទារលើសពីនេះបដិសេធចោល ។

ក្នុងករណីទណ្ឌិតទាំងពីរនាក់ខាងលើគ្មានប្រាក់សងជនរងគ្រោះត្រូវដាក់គុកបង្ខំរូបកាយក្នុងម្នាក់ៗចំនួន ០២ ឆ្នាំដើម្បីទារប្រាក់ជនទណ្ឌ ។ តាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៨ក្រចុះថ្ងៃទី០៨-២-៨២។

៣ - សាលក្រមនេះជំនុំជំរះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ដើម-បណ្ដឹងរដ្ឋប្បវេណី ។ ទើកផ្លូវឧទ្ធរណ៍ពីរខែគិតពីថ្ងៃប្រកាសសាលក្រម ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៥៧ ចុះថ្ងៃទី០៥-៥-៩៦ របស់ឈ្មោះសេក សំបូរ និងឈ្មោះ ជា ស៊ីអៀង ដែលប្ដឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៦០ ចុះថ្ងៃទី២៨ ខែកុម្ភៈឆ្នាំ១៩៩៦ របស់តុលាការខេត្តបាត់ដំបង លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា : តាមលិខិតរបស់មេធាវីព្យបញ្ហាក់យ៉ាងច្បាស់អំពីស្នាមរបួសរបស់ជនរងគ្រោះហើយ សូមស្នើសុំអោយតុលាការពិចារណា ។ យល់ថាសាលក្រមរបស់តុលាការថ្នាក់ក្រោម ក៏បានសំរេចត្រឹមត្រូវដែរ សូមស្នើសុំអោយតុលាការតម្កល់ទុកជាបានការ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤ - ៤ - ៩៦ របស់ឈ្មោះ លោក សំបូរ និង ជា លីអៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - តម្កល់សាលក្រមលេខ៦០ ចុះថ្ងៃទី ២៩ - ០២ - ៩៦ របស់តុលាការខេត្តបាត់ដំបងទុកជាបានការ ដោយគ្រាន់តែបដិសេធចោលការផ្តន្ទាទោសឈ្មោះ លោក សំបូរ ពីបទជេរប្រមាថ តាមមាត្រាទី៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ត្រង់ចំណុចទី១ - ក នៃសាលក្រម ។

៣ - អោយឈ្មោះ ទេង គឹមហួយ រួចខ្លួនពីបទចោទប្រកាន់ពីបទបង្ករបួសស្នាមដោយចេតនា តាមមាត្រាទី៤១ នៃច្បាប់ព្រហ្មទណ្ឌប្រព្រឹត្តនៅថ្ងៃទី ២២ - ៩ - ៩៤ នៅឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

៤ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីតប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៤២ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះ - លោក សំបូរ និង ជា លីអៀង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១២ ខែ មិនា ឆ្នាំ ១៩៩៩ របស់ឈ្មោះ លោក សំបូរនិង ជា លីអៀង ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ១៩៩៩ របស់ឈ្មោះហ៊ឹម ទី ជាចុងបណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា ៖ មានភិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ លោក សំបូរ និងជា លីអៀង ពីបទ បង្ករបួសស្នាមដោយចេតនា កាលពីថ្ងៃទី ២២ - ៩ - ១៩៩៤ ប្រព្រឹត្តនៅភូមិ២០ឧសភា ឃុំកក្កាព ស្រុក - ខេត្តបាត់ដំបង បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១.៦៣.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

សាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី១២ខែសីហាឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍សំរេចមានលក្ខណៈត្រឹមត្រូវទាំងទំរង់និងគតិច្បាប់ ។

- បានស្តាប់សំណោលសារណារបស់ជនជាប់ចោទឈ្មោះ លោក សំបូរ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះជា លីអៀង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថា ក្នុងរឿងនេះឈ្មោះ ហ៊ឹម ទី ជាអ្នកបង្កហេតុមុន ដោយចាប់កូនខាងខ្ញុំវាយធ្វើបាប ទើបខាងខ្ញុំរុះទៅជួយកូន សូមតុលាការពិនិត្យ ពិចារណា ។

- បានស្តាប់ចម្លើយដោះសាររបស់ឈ្មោះ យឹម នី ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថា: ក្នុងរឿងនេះគឺកូនរបស់ឈ្មោះ សោក សំបូរ ជាអ្នកបង្ក ហើយប្អូនខាងខ្ញុំ តេង គីមហួយ គ្រាន់តែនាំគេឯងនោះមកអោយឪពុក ម្តាយរបស់គេធ្វើការអប់រំណែនាំប៉ុណ្ណោះ ក៏ប៉ុន្តែត្រូវឈ្មោះ សោក សំបូរ និងប្រពន្ធឈ្មោះ ផា ស៊ីអៀង ព្រួតគ្នាវាយមកលើឈ្មោលអោយមានរបួស ខាងខ្ញុំឃើញដូច្នេះក៏ចូលទៅជួយឃាត់ ក៏ត្រូវឈ្មោះ សោក សំបូរ វាយមកលើខាងខ្ញុំថែមទៀត ។ សូមតុលាការមេត្តាពិនិត្យ ពិចារណា ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក គង់ ពិសី ជាមេធាវីការពារអោយជនជាប់ចោទនៅពេលជំនុំជំរះថា: ផ្លូវការតែការលួចដេញដោយឃើញថាឈ្មោះ តេង គីមហួយ និងឈ្មោះ យឹម នី ជាអ្នកវាយធ្វើបាបកុមារ សោក សំអៀត មុនទើបធ្វើអោយឈ្មោះ សោក សំបូរ និងម្តាយឈ្មោះ ផា ស៊ីអៀង ទប់ចិត្តពុំបាន ហេតុនេះសូមតុលាការមេត្តាពិនិត្យពិចារណា ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ ចម្លើយដោះសាររបស់ជនរងគ្រោះនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥២ ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះ សោក សំបូរ និងឈ្មោះ ផា ស៊ីអៀង ធ្វើឡើងក្នុងអំឡុងច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ផា ស៊ីអៀង ដែលបានវាយទៅលើឈ្មោះ យឹម នី និងប្អូនឈ្មោះ តេង គីមហួយ កាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ នៅភូមិ ២០ ឧសភា ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥១ និង៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយឈ្មោះ សោក សំបូរ រួចខ្លួនពីបទជេរប្រមាថ និងអោយឈ្មោះ តេង គីមហួយ រួចខ្លួនពីបទបង្ករបួសស្នាមដោយចេតនា នោះជាការត្រឹមត្រូវហើយ ។

- យល់ឃើញថា ការលើកឡើងរបស់អ្នកស្រី ផា ស៊ីអៀង ក្នុងសារណាចុះថ្ងៃទី១២ខែមិនា ឆ្នាំ ១៩៩៩ ដែលជូនមកតុលាការកំពូលនោះសុទ្ធតែជារឿងនៃអង្គហេតុ ដែលតុលាការថ្នាក់ក្រោមពិចារណារួចហើយ ។

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូលហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់និងគតិច្បាប់ហើយ ។

ដោយហេតុនេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ៤២ ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៨ របស់លោក ណោក លេក-លំបូរ និងអ្នកស្រី ជា សីវៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៧៣ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ៣ ខែ ធ្នូឆ្នាំ១៩៩៩ ។